**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# របាយការណ៍
# កិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែមករា ឆ្នាំ២០២២
# ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី

នៅព្រឹកថ្ងៃអង្គារ ១៥រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥ ត្រូវនឹងថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២២ អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រៀបចំកិច្ចប្រជុំថ្នាក់ដឹកនាំប្រចាំខែមករា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមទេសរដ្ឋមន្ត្រី **អៀង មូលី** ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ កិច្ចប្រជុំនេះមានការចូលរួមពី ឯកឧត្តម លោកជំទាវ ជាអនុប្រធាន អគ្គលេខាធិការ នាយក-នាយករងខុទ្ទកាល័យ អគ្គលេខាធិការរង ទីប្រឹក្សា ជំនួយការ ប្រធាននាយកដ្ឋាន នៅក្នុងសាលប្រជុំ "ខ" ដោយឡែកចំពោះ លោក អ្នកស្រី អ្នកនាងកញ្ញា អនុប្រធាននាយកដ្ឋាន ប្រធានការិយាល័យ និងអនុការិយាល័យ និងមន្ត្រីនៃអ.ជ.ប.ជ.អ ចូលរួមតាមបណ្តាញវីដេអូ កម្មវិធី Zoom។

## គោលបំណងនៃកិច្ចប្រជុំ:

- ដើម្បីរាយការណ៍ពីបច្ចុប្បន្នភាពនៃសកម្មភាពរបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- ដើម្បីបានដឹងពីស្ថានភាពរាលដាល និងគោលដៅនៃការឆ្លើយតបនឹងមេរោគអេដស៍ និងបទអន្តរាគមន៍។
- ដើម្បីបានដឹងពីសមិទ្ធផលដែលសម្រេចបាន និងឧបសគ្គដែលកើតមានឡើងក្នុងការអនុវត្តផែនការសកម្មភាព និងលើកផែនការសកម្មភាពអនុវត្តសម្រាប់ខែបន្ទាប់។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមទេសរដ្ឋមន្ត្រី មានប្រសាសន៍ស្វាគមន៍ ដល់មន្ត្រីរាជការទាំងអស់ដែលបានចូលរួម និងបានជម្រាបជូនពីដំណើរការនៃកិច្ចប្រជុំតាមរបៀបវារៈដូចខាងក្រោម ៖

១) បទបង្ហាញរបាយការណ៍សង្ខេបស្តីពីលទ្ធផលសកម្មភាពការងារប្រចាំខែមករា និងទិសដៅការងារខែកុម្ភៈ ឆ្នាំ២០២២ ដោយឯកឧត្តម **ឈឹម ឃិនដារ៉េត**។

២) បទបង្ហាញស្តីពីទិសដៅខាងមុខនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងចរន្តជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយឯកឧត្តម **រស់ សីលវ៉ាត់** និងឯកឧត្តម **ធា ផលា** អនុប្រធានទទួលបន្ទុកបច្ចេកទេស។

៣) មតិសំណេះសំណាលរបស់ឯកឧត្តម ទេសរដ្ឋមន្ត្រី

៤) កិច្ចការផ្សេងៗ។

បន្ទាប់មក ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតជូន ឯកឧត្តម អគ្គលេខាធិការ ធ្វើបទបង្ហាញ។ ដោយមានការ អនុញ្ញាតពី ឯកឧត្តមទេសរដ្ឋមន្ត្រី ឯកឧត្តម **ឈឹម ឃិនដារ៉េត** អគ្គលេខាធិការ បានធ្វើបទបង្ហាញស្តីពី ៖

## I- បទបង្ហាញរបាយការណ៍ស្តីពីលទ្ធផលសកម្មភាព ការងាររបស់ថ្នាក់ដឹកនាំ និងអគ្គលេខាធិការដ្ឋាន

### ១- សកម្មភាពការងារដែលសម្រេចបាន ៖

- សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការពិនិត្យឡើងវិញផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (២០១៩-២០២៣)។
- បានធ្វើវិបស្សនាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ឆ្នាំ២០២២។
- បានប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍លើកទី១ ឆ្នាំ២០២២ ។
- បន្តចុះបណ្តុះបណ្តាលការត្រួតពិនិត្យ ការអនុវត្តសជណ២១៣ តាមរាជធានី ខេត្តគោលដៅ។
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់ថវិកាចំនួន៨០លានរៀលដល់ រាជធានី និងខេត្តទាំង៣ រួចហើយក្នុងការអនុវត្តគម្រោងទីក្រុងពន្លឿនឆ្លើយតបនឹងជំងឺអេដស៍ (Fast Track City)។
- បន្តធ្វើការងារជាមួយក្រសួងមហាផ្ទៃ ដើម្បីជំរុញគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍ថ្នាក់ក្រោមជាតិ។

### ២- បញ្ហាប្រឈម ៖

ស្ថានភាពជំងឺកូវីដ១៩ នៅតែបន្តផលប៉ះពាល់ការងារឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍។

### ៣- ទិសដៅអនុវត្តបន្ត

- ពិនិត្យកែសម្រួលសេចក្តីសម្រេចលេខ១៣៦ស្តីពីការតែងតាំងសមាសភាពក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។
- រៀបចំក្រុមប្រឹក្សាបច្ចេកទេសសម្រាប់តាមដានការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ។
- បន្តចុះបណ្តុះបណ្តាលការត្រួតពិនិត្យការអនុវត្តសជណ២១៣ តាមបណ្តារាជធានី ខេត្តគោលដៅ
- បន្តធ្វើការងារជាមួយក្រសួងមហាផ្ទៃ ដើម្បីជំរុញដល់ការបង្កើតគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍នៅថ្នាក់ក្រោមជាតិ។
- រៀបចំធាតុចូលសម្រាប់របាយការណ៍របស់ការិយាល័យឧត្តមស្នងការ ទទួលបន្ទុកសិទ្ធិមនុស្សក្នុងបរិបទជំងឺHIV/AIDS របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។
- ត្រៀមរៀបចំផ្សព្វផ្សាយការយល់ដឹងអំពីការទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ក្នុងទិវានៃសេចក្តីស្រឡាញ់។
- រៀបចំកិច្ចប្រជុំក្រុមប្រឹក្សាបច្ចេកទេសអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទី២។

## II- បទបង្ហាញ ស្តីពីទិសដៅការងារខាងមុខនៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងចរន្តជាតិឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍

**បទបង្ហាញដោយឯកឧត្តម សេ សីលវ៉ាត់ ៖**

- ឯកឧត្តមបានសង្ខេបជូនថ្នាក់ដឹកនាំ និងអង្គប្រជុំអំពីទិសដៅនៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (NSPV) ក្រោយពេលធ្វើការពិនិត្យឡើងវិញ មានដូចជាៈ
- ទស្សនៈវិស័យរបស់ប្រទេសកម្ពុជា គឺគ្មានមេរោគអេដស៍ និងជំងឺអេដស៍ ហើយប្រជាពលរដ្ឋមានសុខភាពកាន់តែប្រសើរឡើង។
- គោលបំណងយុទ្ធសាស្ត្រទាំង៤ ទី១) ផ្តល់សេវាបង្ការ ថែទាំ និងព្យាបាលយ៉ាងទូលំទូលាយ តាមរយៈការឆ្លើយតបជាពហុវិស័យ ទី២)ធ្វើសមាហរណកម្មមេរោគអេដស៍ក្នុងប្រព័ន្ធសុខាភិបាល និងក្រសួងពាក់ព័ន្ធឱ្យបានទូលំទូលាយ ទី៣) ពង្រីកការការពារសង្គម និងការទទួលបានសេវាសង្គមតាមផ្លូវច្បាប់សម្រាប់អ្នកផ្ទុកមេរោគអេដស៍ និងក្រុមប្រជាជនគន្លឹះ ទី៤)បង្កើនការផ្តល់ហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាលឱ្យបាន ៥០%នៅឆ្នាំ២០២៣ ។
- មានយុទ្ធសាស្ត្រចំនួន៥ ដែលបានភ្ជាប់ទៅនឹងគោលបំណងទាំង៤ខាងលើ។
- កញ្ចប់អន្តរាគមន៍អាទិភាពក្នុងយុទ្ធសាស្ត្រនីមួយៗ ដែលឯកឧត្តមបានជម្រាបថានឹងត្រូវក្លាយជាផែនទីបង្ហាញផ្លូវសម្រាប់ថ្នាក់ដឹកនាំអាជ្ញាធរជាតិ និងអគ្គលេខាធិការដ្ឋាន ប្រើប្រាស់ក្នុងការសម្របសម្រួល ក៏ដូចជាក្នុងការត្រួតពិនិត្យតាមដាន និងវាយតម្លៃ លើការអនុវត្តការងារឆ្លើយតបនឹងមេរោគអេដស៍ ដើម្បីឈានទៅសម្រេចគោលដៅនៃការបិទបញ្ចប់ការរាលដាលមេរោគអេដស៍នាឆ្នាំ២០២៥។

**បទបង្ហាញដោយ ឯកឧត្តម ទា ផលា ៖**

ឯកឧត្តមបានបង្ហាញនូវៈ

- យុទ្ធសាស្ត្រថ្មីរបស់មូលនិធិសកលដែលទើបត្រូវបានអនុម័ត គឺការជម្រុញអោយ ដាក់មនុស្ស និងសហគមន៍ (ងាយរងគ្រោះ) ជាចំណុចស្នូលកណ្តាលក្នុងការដឹកនាំការឆ្លើយតបនឹងជំងឺអេដស៍ ជំងឺរបេង និងជំងឺគ្រុនចាញ់ ព្រមទាំងក្នុងការពង្រឹងប្រព័ន្ធសម្រាប់សមធម៌ក្នុងការទទួលសេវាសុខភាព និងពង្រឹងភាពត្រៀមលក្ខណៈបានក្នុងការឆ្លើយតបនឹងការរាលដាលជំងឺ ដែលមានលក្ខណៈពិសេសស៊ីសង្វាក់គ្នានឹងទស្សនវិស័យរបស់អ.ជ.ប.ជ.អ. ដូចជា ទី១)- ***ពង្រឹងភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់ការ*** (Leadership and ownership) ទី២)- ***ពង្រឹងភាពជាដៃគូ*** (Partnership) ទី៣)- ***ការវិនិយោគ*** (Investment) ដោយដាក់មនុស្ស និងសហគមន៍ នៅចំណុចកណ្តាលនៃការឆ្លើយតបនឹងជំងឺអេដស៍។
- ផែនការឆ្នាំ២០២២របស់ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអាមេរិកសម្រាប់ការងារសុខភាពកម្ពុជា ដែលគាំទ្រចក្ខុវិស័យយុទ្ធសាស្ត្ររបស់កម្ពុជា ក្នុងការលុបបំបាត់មេរោគអេដស៍នៅឆ្នាំ ២០២៥ ដោយពង្រឹងការរៀបចំជាគោលនយោបាយ ការអនុវត្ត និងរៀបចំប្រព័ន្ធសុខាភិបាលប្រកបដោយសមធម៌ និងនិរន្តរភាព លើកកម្ពស់យុត្តិធម៌ កាត់បន្ថយវិសមភាព និងដោះស្រាយគ្រប់វិស័យជូនប្រជាជន ព្រមទាំងគោរព និងការពារសិទ្ធិមនុស្ស និងសមភាពយេនឌ័រ។លើកកម្ពស់ភាពជាម្ចាស់ និងគណនេយ្យភាពនៃបណ្តាញ និងដៃគូពាក់ព័ន្ធនៃភ្នាក់ងាររាជរដ្ឋាភិបាល សង្គមស៊ីវិល និងវិស័យឯកជន។

- បច្ចុប្បន្នភាពនៃការរាលដាលមេរោគអេដស៍ ដោយផ្តោតលើនិន្នាការប្រឈមពីរសំខាន់ដែលយើងត្រូវរកគ្រប់អន្តរាគមន៍ដើម្បីធ្វើការគ្រប់គ្រងអោយជាប់ គឺចំនួនអ្នកឆ្លងថ្មីប្រមាណ១១០០នាក់ក្នុង១ឆ្នាំ និងចំនួនអ្នកមិនទាន់ដឹងស្ថានភាពរបស់ខ្លួនប្រមាណ១២០០០នាក់។ ក្នុងនោះក្រុមប្រជាជនប្រឈមមុខខ្ពស់ពិសេសបុរសស្រលាញ់បុរស នៅតែជាចំនុចស្នូលនៃការឆ្លងរាលដាល ដែលត្រូវការអន្តរាគមន៍ដ៏មានប្រសិទ្ធភាពសម្រាប់ឆ្លើយតបពិសេស ប្រើប (PrEP) HIVST, Condom, NSP, BCC, PNTT។

  និងតម្រូវការរំកិល អន្តរាគមន៍ពីលក្ខណៈធ្វើកម្មវិធីសុទ្ធសាធទៅកាន់ការរៀបចំកសាងប្រព័ន្ធសុខាភិបាលដែលនឹងគាំទ្រនិរន្តរភាពនៃកម្មវិធី តាមរយៈ

  ក). ការរៀបចំ ស្ថាប័ន GDJ និង TAB ដែលអាចគាំទ្រ ការសម្រេចចិត្តត្រឹមត្រូវរបស់ PAB ក្នុងនោះត្រូវ ទី១) ពង្រឹងសមាជិកភាព តួនាទី និងការទទួលខុសត្រូវ ទី២) មានគោលការណ៍ ការណែនាំនៃអន្តរកម្ម បញ្ជីអ្នកចូលរួម របាយការណ៍កិច្ចប្រជុំ ទី៣) ភារកិច្ច និងលទ្ធផលដែលស្ថាប័នជាសមាជិកត្រូវចូលរួមទាក់ទងនឹងយុទ្ធសាស្ត្រនីមួយៗ។

  ខ). ការពង្រឹងតួនាទី និងគណនេយ្យភាពរបស់អ្នកពាក់ព័ន្ធ នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ទាំងស្ថាប័នរដ្ឋ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីធានានូវការទទួលខុសត្រូវក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៥ (NSPV)។

  គ). ពង្រឹងគោលការណ៍ដឹកនាំការឆ្លើយតបការរាលដាល ដោយយកប្រជាពលរដ្ឋអ្នកទទួលផលជាធំជាស្នូលកណ្តាល និងបង្កើនកិច្ចសន្ទនារវាងអ្នកធ្វើគោលនយោបាយ ជាមួយអ្នកផ្តល់សេវា និងពលរដ្ឋអ្នកទទួលផល ក្នុងគ្រប់ការពិនិត្យលើបញ្ហានិងការដាក់ចេញនូវដំណោះស្រាយសម្រាប់បញ្ហា។

**លោកជំទាវ ស៊ឹម ខេងខាំ**

- ស្នើសុំរៀបចំប្រារព្ធទិវានារីអន្តរជាតិ៨មីនា ខួបលើកទី ១១១ នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ក្រោមប្រធានបទ *សមភាពយេនឌ័រថ្ងៃនេះ ដើម្បីចីរភាពនាពេលអនាគត។*
- **សម្តេចតេជោ** បានអនុញ្ញាតឱ្យក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ទៅរាយការណ៍ស្តីពីលទ្ធផលបូកសរុបការងារប្រចាំឆ្នាំ នាថ្ងៃទី២១ខែកុម្ភៈ ឆ្នាំ២០២២។

## III- មតិសំណេះសំណាលរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី

បន្ទាប់មក កិច្ចប្រជុំបានដំណើរការបន្តនៅក្នុងរបៀបវារៈទី៣ ក្នុងនោះឯកឧត្តមទេសរដ្ឋមន្ត្រី បានមានប្រសាសន៍សំណេះសំណាល និងផ្តល់នូវអនុសាសន៍លើចំណុចសំខាន់ៗដូចខាងក្រោម ៖

១- ដើម្បីសម្រេចគោលដៅ អគ្គលេខាធិការត្រូវធ្វើការទៅតាមមុខសញ្ញាយុទ្ធសាស្ត្រជាតិ នៅឆ្នាំ២០២២។

២- ការរៀបចំប្រកិច្ចជុំត្រូវតាមលំដាប់លំដោយគ្នា ឱ្យស៊ីសង្វាក់គ្នា ដូចជាការប្រជុំក្រុមប្រឹក្សាបច្ចេកទេសរួច អគ្គលេខាធិការរាយការណ៍ជូនអង្គប្រជុំថ្នាក់ដឹកនាំ អ.ជ.ប.ជ.អ។ អង្គប្រជុំថ្នាក់ដឹកនាំផ្តល់ព័ត៌មានត្រឡប់ ដើម្បីឱ្យអគ្គលេខាធិការកែសម្រួលឡើងវិញ ហើយចាត់វិធានការឱ្យមានប្រសិទ្ធភាព។

៣- ពង្រឹងសកម្មភាពការងារបុរសរួមភេទជាមួយបុរស (MSM) ពីព្រោះ MSM ជាមុខសញ្ញានៃការរីករាលដាលឡើងវិញនៃជំងឺអេដស៍។

៤- ថ្នាក់ដឹកនាំត្រូវពិនិត្យមើលឡើងវិញលើរបាយការណ៍ និងតួលេខរបស់ UNAIDS ឆ្នាំ២០២១ និង *សេចក្តីថ្លែងការណ៍នយោបាយឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍* (Political Declaration on HIV and AIDS។

៥- កែសម្រួលផែនការយុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍លើកទី៦(NSP6) ប្រមូលទិន្នន័យឱ្យបានច្រើនជាទីបំផុត និងដាក់ធាតុចូលឱ្យបានច្រើនចាប់ពីពេលឥឡូវ។

៦- ត្រូវប្រជុំពិភាក្សាគ្នាពីយុទ្ធសាស្ត្រណាមួយដែលមានបញ្ហាស្មុគស្មាញជាងគេ និងចាំចាច់បំផុត យកមកធ្វើផែនការសកម្មភាព ហើយដឹកនាំស្ថាប័ន និងដៃគូនានា ក្នុងការតម្រង់មុខសញ្ញាដើម្បីអនុវត្ត។

៧- ការប្រជុំថ្នាក់ដឹកនាំ NAA ត្រូវប្រជុំយ៉ាងតិច ៣ថ្ងៃក្រោយ *ប្រជុំក្រុមប្រឹក្សាបច្ចេកទេស* (Technical Advisory Board) ត្រូវប្រមូលរបាយការណ៍វឌ្ឍនភាពពីក្រុមការងារតាមយុទ្ធសាស្ត្រ។

៨- អគ្គលេខាធិការត្រូវជំរុញការងារជាមួយក្រសួង ស្ថាប័ននានា ដែលមានការទទួលខុសត្រូវទូទាំងប្រទេស មានការកិច្ចត្រួតពិនិត្យ សម្របសម្រួល និងណែនាំអនុវត្តសកម្មភាពតាមយុទ្ធស្រាស្ត្រនីមួយៗ ដោយមានសូចនាករច្បាស់លាស់ ។

៩- ត្រូវរុករកអ្នកដែលបាត់ចំនួន១២,000ករណី ដោយសហការជាមួយ NCHADS, UNAIDS និងស្ថាប័នពាក់ព័ន្ធទាំងអស់។

១០- ការធ្វើតេស្តរុករកមេរោគអេដស៍លើអនិតិជន អាចធ្វើបាន អាស្រ័យលើគ្រូពេទ្យផ្តល់ការអប់រំដល់ក្រុមគ្រួសារឱ្យយល់ច្បាស់ពីសារប្រយោជន៍នៃការធ្វើរោគវិនិច្ឆ័យ ដើម្បីជួយសង្គ្រោះកុមារ ដោយមានការព្យាបាលបានត្រឹមត្រូវ មានវិធានការការពារខ្លួន និងតាមដានសុខភាព។

១១- ជៀសវាងការផ្សព្វផ្សាយកព័ត៌មានសម្ងាត់ដែលធ្វើឱ្យប៉ះពាល់ដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់អ្នកផ្ទុកមេរោគអេដស៍។

១២- ឯកឧត្តមទេសរដ្ឋមន្ត្រី បានអនុញ្ញាតឱ្យមានការរៀបចំប្រារព្ធទិវានារីអន្តរជាតិ៨មីនា នៅ អ.ជ.ប.ជ.អ និងឱ្យមានការរៀបចំវត្ថុអនុស្សាវរីយ៍ជូនដល់ស្ត្រីៗផងដែរ។

១៣- មុនប្រជុំក្រុមប្រឹក្សាបច្ចេកទេស អគ្គលេខាធិការដ្ឋាន ត្រូវរៀបចំអញ្ជើញដៃគូនានាឱ្យចូលរួម មានរបៀបវារៈ មានអ្នកទទួលខុសត្រូវ ដោយតម្រង់ទិសដៅលើយុទ្ធសាស្ត្រសំខាន់ៗ។

១៤- ត្រូវតម្រង់ទិសមូលនិធិសកល (GF) ឱ្យគាត់មកជួយពង្រឹងប្រព័ន្ធជាតិ (country system) ដែលជាយុទ្ធសាស្ត្រជាតិរបស់ អ.ជ.ប.ជ.អ។ ចំពោះ*គណៈកម្មាធិការសម្របសម្រួលថ្នាក់ប្រទេស* (Country Coordination Committee) ឱ្យឯកឧត្តម **ហែម វណ្ណឌី** ចេញសេចក្តីសម្រេចតែងតាំងសមាជិកចូលមកក្នុងក្រុមប្រឹក្សាបច្ចេកទេស អ.ជ.ប.ជ.អ។

១៥- ឯកឧត្តម **ហោ ម៉ុនឡេង** ត្រូវជួយអគ្គលេខាធិការ ដើម្បីពង្រឹងសមត្ថភាពស្តីពីការត្រួតពិនិត្យតាមដាន និងវាយតម្លៃ (M&E) ។

ជាទីបញ្ចប់ ឯកឧត្តមទេសរដ្ឋមន្ត្រី បានលើកទឹកចិត្ត និងណែនាំឱ្យមន្ត្រីទាំងអស់ បន្តកិច្ចខិតខំប្រឹងប្រែងទាំងអស់គ្នា ដោយយកចិត្តទុកដាក់ក្នុងការអនុវត្តការងារឱ្យចំទិសដៅ និងពហុវិស័យឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ តាមយន្តការយុទ្ធសាស្ត្រនីមួយៗឱ្យកាន់តែប្រសើរឡើង។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង១១:២៥នាទី ប្រកបដោយបរិយាកាសរីករាយ និងស្និទ្ធស្នាលក្រៃលែង។

ថ្ងៃពុធ ១កើត ខែមាឃ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២២

**អ្នកធ្វើរបាយការណ៍**

**ស៊ុត_ថនផាន់**

បានឃើញ និងឯកភាព

ទេសរដ្ឋមន្ត្រី ប្រធាន អ.ជ.ប.ជ.អ

**អៀង_មូលី**